ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# វិធានការគោលនយោបាយ
# ជំរុញចលនាទេសចរណ៍ផ្ទៃក្នុង
# ឆ្នាំ២០២១-២០២៣

អនុម័តដោយរាជរដ្ឋាភិបាល ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# វិធានការគោលនយោបាយ
# ជំរុញចលនាទេសចរណ៍ផ្ទៃក្នុង
# ឆ្នាំ ២០២១ - ២០២៣

អនុម័តដោយរាជរដ្ឋាភិបាល ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១

# អារម្ភកថា

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនារីករាយថ្លែងនូវសារលិខិតជូនជនរួមជាតិទាំងអស់ជាទីស្នេហា អំពីឆន្ទៈ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល គាំទ្រវិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣។ **វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង**នេះមានចក្ខុវិស័យច្បាស់លាស់សម្រាប់ការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ សំដៅសម្រេចឱ្យបានចំនួនភ្ញៀវទេសចរផ្ទៃក្នុង ប្រមាណ ១១លាននាក់ នៅឆ្នាំ២០២៣។

ជំងឺកូវីដ-១៩ បានបង្កឱ្យមានវិបត្តិសុខភាពសាធារណៈ និងផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះសេដ្ឋកិច្ច-សង្គម ស្ទើរគ្រប់វិស័យ សម្រាប់កម្ពុជា តំបន់ និងសកលលោក។ វិបត្តិនេះបានធ្វើឱ្យចំនួនភ្ញៀវទេសចរអន្តរជាតិមកទស្សនាកម្ពុជាធ្លាក់ចុះ ៨០,២% និងភ្ញៀវទេសចរក្នុងស្រុកធ្លាក់ចុះក្នុងរង្វង់ប្រមាណ ២០% ជាមួយនឹងការខាតបង់ប្រាក់ចំណូលប្រមាណ ៣ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២០។ ប្រឈមនឹងវិបត្តិដ៏ស្រួចស្រាវនេះ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តដាក់ចេញ**ផែនទីចង្អុលផ្លូវស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩** ដែលជាឯកសារយុទ្ធសាស្ត្រជាមូលដ្ឋានសម្រាប់ការរៀបចំវិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនេះឡើង ដោយផ្តោតយ៉ាងសំខាន់លើការថ្លឹងថ្លែង រវាងកម្រិតហានិភ័យនៃការឆ្លងក្នុងតំបន់ ដែលត្រូវអនុញ្ញាតឱ្យមានសកម្មភាព ទេសចរណ៍ពេញលេញឡើងវិញ ព្រមទាំងសមត្ថភាពក្នុងការឆ្លើយតបទាន់ពេលវេលា និងផលប្រយោជន៍សេដ្ឋកិច្ចដែលទទួលបានសម្រាប់ប្រទេសជាតិ។

ទន្ទឹមនឹងការត្រៀមបើកទទួលទេសចរណ៍វ៉ាក់សាំងនៅចុងឆ្នាំ២០២១ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមដាក់ចេញនូវយុទ្ធនាការ **"ទស្សនាស្រុកយើង"** ក្រោមស្មារតី **"ស្រលាញ់ជាតិ ត្រូវស្គាល់ទឹកដី"** សំដៅជំរុញចលនាទេសចរណ៍ផ្ទៃក្នុង តាមរយៈការបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋអាចធ្វើដំណើរបានទូទាំងប្រទេស ប្រកបដោយសុវត្ថិភាព និងក្តីសប្បាយរីករាយ។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះក្រសួងទេសចរណ៍ និងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានសហការគ្នាធ្វើឱ្យវិធានការគោលនយោបាយនេះ បានលេចចេញជារូបរាង ហើយត្រូវបានអនុម័ត និងបានក្លាយជាឯកសារដ៏មានតម្លៃបំផុតសម្រាប់ជាតិយើង។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវគ្រប់ក្រសួង-ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន ក៏ដូចជាប្រជាជនទាំងអស់ សូមចូលរួមគាំទ្រ និងរួមចំណែកឱ្យបានសកម្មក្នុងការអនុវត្តវិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុងឱ្យទទួលបានជោគជ័យជាស្ថាពរ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា វិធានការគោលនយោបាយនេះ ក្លាយជាត្រីវិស័យក្នុងការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ផ្ទៃក្នុង ប្រកបដោយចីរភាព គុណភាព សុវត្ថិភាព និរន្តរភាព ការទទួលខុសត្រូវ និងបរិយាប័ន្ន។

**ថ្ងៃ**អង្គារ ៧កើត **ខែ**អស្សុជ **ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥**

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី** ១២ **ខែ** តុលា **ឆ្នាំ២០២១**

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


១. សេចក្តីផ្តើម ........................................................................ ១

២. ទស្សនវិស័យទេសចរណ៍ផ្ទៃក្នុង ........................................................ ២

២.១. ការវាយតម្លៃស្ថានភាព និងនិន្នាការទេសចរណ៍ផ្ទៃក្នុង ........................ ២

២.២. បញ្ហាប្រឈម ........................................................................ ៣

២.៣. កត្តាកំណត់ភាពជោគជ័យនៃការជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ..................៤

៣. វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ...............................៥

៣.១. ការលើកកម្ពស់ទំនុកចិត្ត និងភាពជឿជាក់របស់ភ្ញៀវទេសចរផ្ទៃក្នុង ...................៥

៣.២. ការជំរុញដំណើរការឡើងវិញរបស់អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍តាមគន្លងប្រក្រតីភាពថ្មី .. ៧

៣.៣. ការបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរផ្ទៃក្នុង .....................................៩

៣.៤. ការអភិវឌ្ឍផលិតផលទេសចរណ៍បម្រើឱ្យចលនាទេសចរណ៍ផ្ទៃក្នុង .................... ១១

៣.៥. ការផ្សព្វផ្សាយ ការអប់រំ និងការបណ្តុះបណ្តាលការយល់ដឹងជាសាធារណៈ ......................... ១៣

៤. យន្តការអនុវត្ត ........................................................................១៥

៤.១. យន្តការស្ថាប័ន ....................................................................១៥

៤.២. ផែនការសកម្មភាព .................................................................. ១៦

៥. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ............................................... ១៦

៦. សន្និដ្ឋាន ............................................................................... ១៧

ឧបសម្ព័ន្ធ.ផែនការសកម្មភាពនៃវិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង........ ១៨

## ១. សេចក្តីផ្តើម

ក្នុងបរិបទនៃការបន្តឆ្លងរាលដាលជំងឺកូវីដ-១៩, តាមការវាយតម្លៃរបស់អង្គការទេសចរណ៍ពិភពលោក (UNWTO) ការជំរុញទេសចរណ៍ផ្ទៃក្នុងជាកាតាលីករប្រកបដោយសក្តានុពលមួយ នៅក្នុងការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញ តាមរយៈការចូលរួមទ្រទ្រង់ដល់ដំណើរការអាជីវកម្មនៅក្នុងវិស័យទេសចរណ៍។ ជាការពិត កម្ពុជាក៏មិនខុសគ្នាពីបណ្តាប្រទេសដទៃលើសកលលោកដែរ វិស័យទេសចរណ៍ត្រូវពឹងលើទេសចរណ៍ផ្ទៃក្នុង ដើម្បីចូលរួមស្រោចស្រង់សេដ្ឋកិច្ច និងស្ថានភាពទេសចរណ៍ជារួមឡើងវិញ។

រាជរដ្ឋាភិបាលកម្ពុជាតែងតែផ្តល់ការយកចិត្តទុកដាក់ខ្ពស់ ក្នុងការជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ដើម្បីជាមូលដ្ឋានសម្រាប់ការត្រៀមបើកទទួលទេសចរណ៍អន្តរជាតិនៅតាមតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ដូចអ្វីដែលជាប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** គូសបញ្ជាក់កាលពីពេលថ្មីៗនេះថា *"[..] ផ្តើមចេញពីការបើកសាលារៀនឡើងវិញ បន្ទាប់មកគឺវិស័យសេវាកម្ម ពិសេសវិស័យទេសចរណ៍ ដែលត្រូវធ្វើឡើងជា ២ជំហាន ដោយជំហានទី១ គឺបើកទេសចរណ៍ផ្ទៃក្នុង និងជំហានទី២ គឺបើកទទួលទេសចរណ៍វ៉ាក់សាំង [..]"*។

ជាមួយកិច្ចខិតខំប្រឹងប្រែងទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមថាយើងនឹងអាចឈានទៅសម្រេចបានទិសដៅក្នុងការទទួលបានចំនួនភ្ញៀវទេសចរផ្ទៃក្នុងប្រមាណ **១១ លាននាក់ នៅឆ្នាំ ២០២៣** ដូចដែលមានចែងក្នុង **"ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩"** ដែលជាឯកសារគោលដ៏មានសារៈសំខាន់ជាយុទ្ធសាស្ត្រ។ ផ្តើមចេញពីផែនទីចង្អុលផ្លូវនេះ បច្ចុប្បន្នកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលទី១ ពោលគឺ ការកសាងភាពធន់ និងត្រៀមឆ្ពោះទៅដំណាក់កាលទី២ នៃការស្តារឡើងវិញវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិនៃជំងឺកូវីដ-១៩។ ក្នុងន័យនេះ **វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង** ត្រូវបានរៀបចំសម្រាប់អនុវត្តចាប់ផ្តើមពីត្រីមាសទី៤ ឆ្នាំ ២០២១ រហូតដល់ឆ្នាំ ២០២៣ ក្រោមយុទ្ធនាការ **"ទស្សនាស្រុកយើង" (Visit Our Home)** ស្របតាមស្មារតី **"ស្រលាញ់ជាតិ ត្រូវស្គាល់ទឹកដី"**។

ជារួម ការរៀបចំវិធានការគោលនយោបាយសម្រាប់ជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនេះ បានផ្តោតយ៉ាងសំខាន់ក្នុងកាថ្លឹងថ្លែង រវាងកម្រិតហានិភ័យនៃការឆ្លងក្នុងតំបន់ ដែលត្រូវអនុញ្ញាតឱ្យមានសកម្មភាពទេសចរណ៍ពេញលេញឡើងវិញ ព្រមទាំងសមត្ថភាពក្នុងការឆ្លើយតបទាន់ពេលវេលា និងផលប្រយោជន៍សេដ្ឋកិច្ចដែលទទួលបានសម្រាប់ប្រទេសជាតិ។ ក្នុងន័យនេះ អភិក្រមនៃការជំរុញទេសចរណ៍ផ្ទៃក្នុងនេះ គឺ **(១).** ការដាក់ចេញនូវវិធានការគាំទ្រ ទាំងវិធានការរដ្ឋបាល និងមិនមែនរដ្ឋបាល, **(២).** ការកំណត់ទីតាំងភូមិសាស្ត្រ ដោយគិតគូរពីសក្តានុពលនិងកម្រិតហានិភ័យ និង **(៣).** ការវាយតម្លៃហានិភ័យ និងកំណត់សូចនាករប្រៀបធៀប (Benchmark Indicators) ដែលអាចវាស់វែងបាន ឬងាយស្រួលក្នុងការពន្យល់។

## ២. ទស្សនវិស័យទេសចរណ៍ផ្ទៃក្នុង

### ២.១. ការវាយតម្លៃស្ថានភាព និងនិន្នាការទេសចរណ៍ផ្ទៃក្នុង

ក្នុងរយៈពេលមួយទសវត្សរ៍, ចំនួនភ្ញៀវទេសចរជាតិកើនឡើងជិតទ្វេដង ពីត្រឹម ៧ លាននាក់ ក្នុងឆ្នាំ ២០០៩ រហូតដល់ ១១,៣ លាននាក់ ក្នុងឆ្នាំ ២០១៩។ យ៉ាងណាមិញ នៅក្នុងឆ្នាំ ២០២០ កម្ពុជាទទួលបានទេសចរណ៍ផ្ទៃក្នុងប្រមាណ ៩ លាននាក់ ថយចុះ ២០% ធៀបនឹងឆ្នាំ២០១៩ ដោយសារការផ្ទុះឡើងនូវវិបត្តិជំងឺកូវីដ-១៩, ដែលជាអត្រាមួយពុំធ្លាប់មានពីមុនមកពោលគឺកម្ពុជាទទួលបានភ្ញៀវទេសចរជាតិត្រឹម ៧,២ លាននាក់ប៉ុណ្ណោះ ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៩។ ក្នុងឆ្នាំ ២០២១, ការផ្ទុះឡើងនៃ **"ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១"** បន្តដាក់សម្ពាធលើវិស័យទេសចរណ៍យ៉ាងធ្ងន់ធ្ងរ។ ជាក់ស្តែង សម្រាប់រយៈពេល ៨ (ប្រាំបី) ខែ ដើមឆ្នាំ ២០២១ កម្ពុជាទទួលបានទេសចរណ៍ផ្ទៃក្នុងប្រមាណ **២,៤២ លាននាក់** ដែលក្នុងនោះភ្ញៀវទេសចរជាតិមានចំនួនប្រមាណជាជាង **២,២៦ លាននាក់** និងភ្ញៀវទេសចរបរទេសផ្ទៃក្នុង មានចំនួនប្រមាណ **១៦ ម៉ឺននាក់** ដោយចំនួនទាំងនេះបានថយចុះប្រមាណជា **៥១% និង៩០%** រៀងគ្នា ធៀបនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំ ២០២០។

មុនពេលមានវិបត្តិនៃជំងឺកូវីដ-១៩, ភ្ញៀវទេសចរជាតិមានទំនោរធ្វើដំណើរកម្សាន្តតាមរដូវកាលជាពិសេសក្នុងអំឡុងត្រីមាសទី ២ (ក្នុងខែ មេសា) ដែលមានថ្ងៃឈប់សម្រាកច្រើន និងមានភាពស្ងប់ស្ងាត់ក្នុងត្រីមាសទី ៣។ ដោយឡែក ក្នុងឆ្នាំ ២០២០, ចំនួនភ្ញៀវទេសចរជាតិចាប់ផ្តើមថមថយពីខែ កុម្ភៈ ដល់ខែ មេសា ក្នុងរង្វង់ -៦១% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៩ ដោយសារភាពភ័យរអាក្នុងការធ្វើដំណើរ ស្របពេលដែលករណីវិជ្ជមានកូវីដ-១៩ ត្រូវបានរកឃើញជាបន្តបន្ទាប់ ទន្ទឹមនឹងការសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការលុបចោលថ្ងៃឈប់សម្រាកពិធីបុណ្យចូលឆ្នាំខ្មែរ។ យ៉ាងណាមិញ, តួលេខនៃភ្ញៀវទេសចរជាតិចាប់ផ្តើមងើបឡើងវិញសន្សឹមៗពីខែ ឧសភា ដល់ខែ តុលា ដែលមានចំនួនភ្ញៀវសរុបប្រហាក់ប្រហែលនឹងឆ្នាំ ២០១៩ ដែរ (ប្រមាណ ៣ លាននាក់) ដោយសារការសម្របខ្លួនតាមគន្លងប្រក្រតីភាពថ្មី មុននឹងថមថយមកវិញក្នុងខែ វិច្ឆិកា ដោយសារ **"ព្រឹត្តិការណ៍ ៣ វិច្ឆិកា"** និង **"ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា"** ដែលជាការឆ្លងរាលដាលក្នុងសហគមន៍ដំបូង។

គួរបញ្ជាក់ផងដែរ, ព្រឹត្តិការណ៍ទាំងពីរនេះត្រូវបានបិទបញ្ចប់ក្នុងអំឡុងចុងខែវិច្ឆិកា និងខែធ្នូ រៀងគ្នា ក្នុងឆ្នាំ ២០២០ ដែលជាបច្ច័យវិជ្ជមានសម្រាប់ការងើបឡើងវិញនៃទេសចរណ៍ផ្ទៃក្នុង។ តួយ៉ាង ចំនួនភ្ញៀវទេសចរជាតិបន្តងើបឡើងក្នុងអំឡុងពេល ២ (ពីរ) ខែ ដើមឆ្នាំ ២០២១, មុននឹងថយចុះយ៉ាងគំហុកក្នុងខែ មីនា និងខែ មេសា ក្នុងអត្រា -៦៦% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០២០, ដោយសារ **"ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១"** ដែលតម្រូវឱ្យមានការដាក់ចេញនូវវិធានការបិទខ្ទប់ និងការបិទរមណីយដ្ឋានទូទាំងប្រទេសក្នុងខែ មេសា។ ទោះជាយ៉ាងនេះក្តី ចាប់ពីខែ ឧសភា ដល់ខែ

កក្កដា ឆ្នាំ ២០២១, ចំនួនភ្ញៀវទេសចរជាតិមានការកើនឡើងវិញ ស្របពេលវិធានការរឹតត្បិតមានសភាពធូរស្រាល ហើយការបិទរមណីយដ្ឋានត្រូវបានបញ្ចប់។ ប៉ុន្តែ, ចំនួនភ្ញៀវទេសចរដែលទទួលបានមានប្រមាណត្រឹម ១/៣ នៃចំនួនភ្ញៀវទេសចរកាលពីឆ្នាំ ២០២០ ប៉ុណ្ណោះ ក្នុងរយៈពេលដូចគ្នា (២៩,៣ ម៉ឺននាក់ ឆ្នាំ ២០២១ ធៀបនឹង ៩២,៩ ម៉ឺននាក់ឆ្នាំ ២០២០)។

ដោយឡែក, គោលដៅទេសចរណ៍ក៏មាននិន្នាការផ្លាស់ប្តូរពីតំបន់សៀមរាប ទៅតំបន់ឆ្នេរសមុទ្រ និងអេកូទេសចរណ៍ ដែលកំពុងទទួលបានការពេញនិយមខ្ពស់។ ជាក់ស្តែង, ចំណែកនៃចំនួនភ្ញៀវទេសចរជាតិដែលធ្វើដំណើរទៅកាន់តំបន់សមុទ្រ និងអេកូទេសចរណ៍ បានកើនឡើងដល់ ៣៩,៨% និង ៨,១% ក្នុងឆ្នាំ ២០២០ ធៀបនឹងអត្រា ២៨,១% និង៥,៨% រៀងគ្នា ក្នុងឆ្នាំ ២០១៩ ខណៈដែលចំនួនភ្ញៀវទេសចរជាតិដែលធ្វើដំណើរទៅកាន់តំបន់សៀមរាបមានចំណែកថមថយមកត្រឹម ១៣,៧% សម្រាប់ឆ្នាំ ២០២០ ធៀបនឹង ២០,៦% ក្នុងឆ្នាំ ២០១៩។

ជារួម ទោះបីជាទេសចរណ៍ផ្ទៃក្នុងមានការថយចុះ ដោយសារការបន្តអូសបន្លាយនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ និងការលេចឡើងនៃមេរោគបំប្លែងថ្មី ក៏ដោយ ក៏នៅតែបន្តមានចលនា តាមរយៈការចល័តរបស់ភ្ញៀវទេសចរនៅក្នុងផ្ទៃប្រទេស ដែលតែងមានសន្ទុះងើបឡើងវិញ នៅរៀងរាល់ពេលដែលសភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មានភាពថមថយ និងស្ងប់ស្ងាត់ជាពិសេស នៅតាមតំបន់គោលដៅនៃរាជធានី-ខេត្ត ដែលមានអត្រានៃការចម្លងមានកម្រិតទាប ឬការឆ្លងក្នុងប្រទេសមានលក្ខណៈជាចង្កោមតាមតំបន់មួយចំនួនដាច់ៗពីគ្នា។

### ២.២. បញ្ហាប្រឈម

តាមការពិគ្រោះយោបល់ជាមួយវិស័យឯកជន, កត្តាចម្បងនៃការធ្លាក់ចុះនៃតម្រូវការ គឺការបាត់បង់ទំនុកចិត្តក្នុងការធ្វើដំណើរ ដោយសារការឆ្លងចូលសហគមន៍ និងការលេចឡើងនៃមេរោគបំប្លែងថ្មី ខណៈដែលកត្តាបន្ទាប់បន្សំមានដូចជា ការធ្លាក់ចុះចំណូល និងកង្វះព័ត៌មានទាក់ទងនឹងគោលដៅទេសចរណ៍ ជាពិសេសទីកន្លែងស្នាក់នៅ និងភោជនីយដ្ឋាន។ ក្នុងន័យនេះ ដើម្បីធានាថាសកម្មភាពទេសចរណ៍ក្នុងស្រុកអាចមានដំណើរការឡើងវិញបាន, ប្រការសំខាន់បំផុត គឺការបង្កើនទំនុកចិត្តរបស់សាធារណជន ក្នុងការសម្រេចចិត្តធ្វើដំណើរកម្សាន្ត។ បន្ថែមលើនេះ, ភាពងាយស្រួលក្នុងការធ្វើដំណើរ ឬរៀបចំសកម្មភាពកម្សាន្តផ្សេងទៀត ក៏ជាកត្តាចាំបាច់ ដើម្បីជំរុញសកម្មភាពទេសចរណ៍ផ្ទៃក្នុង ផងដែរ។

ដោយឡែក ការត្រៀមខ្លួនរួចជាស្រេច (Readiness) នៃអាជីវកម្ម-ប្រតិបត្តិករទេសចរណ៍នានា ក៏ជាកត្តាគន្លឹះមួយទៀត ដើម្បីគាស់ឱ្យសកម្មភាពទេសចរណ៍ក្នុងស្រុកមានដំណើរការឡើងវិញ។ បន្ថែមពីលើនេះ ការដាក់ចេញ និងការអនុវត្តវិធានការនានា រួមមានវិធានការរដ្ឋបាល និងមិនមែនរដ្ឋបាល ដើម្បីទ្រទ្រង់ដំណើរការអាជីវកម្មទេសចរណ៍ក្នុងបរិបទនៃការបន្តឆ្លងជំងឺកូវីដ-១៩ និងដើម្បីសម្រួលដល់ការសម្របខ្លួនទៅនឹងប្រក្រតីភាពថ្មី បានចូលរួមចំណែកដល់ការលើកកម្ពស់ការបង្កើតភាពរស់រវើកឡើងវិញ

នៃប្រភេទអាជីវកម្មទេសចរណ៍ និងបង្កើនភាពទុកចិត្តដល់ភ្ញៀវទេសចរក្នុងការធ្វើដំណើរកម្សាន្ត នៅតាមបណ្តារមណីយដ្ឋាននានានៃរាជធានី-ខេត្ត។

## ២.៣. កត្តាកំណត់ភាពជោគជ័យនៃការជំរុញចលនាទេសចរណ៍ផ្ទៃក្នុង

ក្នុងបរិការណ៍នេះ មុននឹងឈានដល់ការរៀបចំ និងដាក់ចេញវិធានការគោលនយោបាយសម្រាប់ការជំរុញចលនាទេសចរណ៍ផ្ទៃក្នុង រាជរដ្ឋាភិបាលបានធ្វើការវាយតម្លៃលើកត្តាសំខាន់ៗមួយចំនួន ដែលយើងត្រូវបន្តយកចិត្តទុកដាក់ និងលើកកម្ពស់ ដើម្បីផ្តល់លក្ខណៈអំណោយផល និងកំណត់ភាពជោគជ័យក្នុងការជំរុញចលនាទេសចរណ៍ផ្ទៃក្នុងរបស់កម្ពុជា រួមមាន÷

**ទី១)- ល្បឿននៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩÷** គិតចាប់ពីថ្ងៃទី ១០ ខែ កុម្ភៈ ដល់ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០២១ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាជននៅទូទាំងប្រទេសបាន **៩៩,១៦%** **ធៀបជាមួយចំនួនប្រជាជនគោលដៅ ១០លាននាក់** និងលើកុមារ-យុវវ័យអាយុពី ១២ឆ្នាំ ទៅក្រោម ១៨ឆ្នាំ មាន **៨៩,៧២% ធៀបជាមួយចំនួនប្រជាជនគោលដៅប្រមាណ ២លាននាក់**។ ការសម្រេចបានយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ក្នុងល្បឿនដ៏លឿន ឆ្ពោះទៅរកភាពស៊ាំសហគមន៍នេះ បានលើកកម្ពស់ទំនុកចិត្ត និងជំរុញឱ្យប្រជាជនដែលជាភ្ញៀវទេសចរផ្ទៃក្នុង មានទំនោរធ្វើដំណើរកម្សាន្តឡើងវិញ នៅតាមគោលដៅទេសចរណ៍នៅតាមបណ្តារាជធានី-ខេត្តនានា។

**ទី២)- ស្ថានភាពនៃការគ្រប់គ្រងជំងឺកូវីដ-១៩÷** ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជាអាចវាយតម្លៃបានថាស្ថិតនៅក្រោមការគ្រប់គ្រងបានល្អប្រសើរ ដោយអាត្រាការឆ្លង និងអាត្រាស្លាប់ស្ថិតនៅកម្រិតមួយត្រឹង ទោះបីជាមានការឆ្លងនូវមេរោគបំប្លែងថ្មី ក៏ដោយ។ លទ្ធផលប្រកបដោយសុទិដ្ឋិនិយមនេះ កើតចេញពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រគ្រប់គ្រង និងឆ្លើយតបវិបត្តិនៃជំងឺកូវីដ-១៩ ទាំងការបង្ការ ការគ្រប់គ្រង និងការកាត់បន្ថយការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ តាមរយៈការដាក់ចេញនូវវិធានការត្រឹមត្រូវ និងទាន់ពេល រួមមាន យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងដូសជំរុញ, ការពង្រឹងសមត្ថភាពធ្វើតេស្ត ពិសេស ការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩, ការពង្រឹងសមត្ថភាពឆ្លើយតប និងការព្យាបាលជំងឺកូវីដ-១៩, ការអនុវត្តយ៉ាងម៉ឺងម៉ាត់ខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល, វិធានការច្បាប់, វិធានការរដ្ឋបាល, ការផ្សព្វផ្សាយ ការអប់រំ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈ ព្រមទាំងការចូលរួមរបស់សាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់។

**ទី៣)- ការត្រៀមខ្លួនរបស់អាជីវកម្មទេសចរណ៍តាមគន្លងប្រក្រតីភាពថ្មី (New Normal)÷** ការផ្តោតយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងខ្សែច្រវាក់ផលិតកម្មនៃវិស័យទេសចរណ៍ ពីដើមខ្សែដល់ចុងខ្សែ រួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, មធ្យោបាយធ្វើដំណើរ, សម្បទាទេសចរណ៍, ធនធានមនុស្សក្នុងវិស័យទេសចរណ៍, ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍, និងការអនុវត្តតាមនីតិវិធីប្រតិបត្តិ

ស្តង់ដា (SOP) រហូតដល់ការធ្វើពិពិធកម្មផលិតផលទេសចរណ៍ ស្របតាមបរិបទថ្មីនៃតម្រូវការ និងការផ្គត់ផ្គង់របស់ទីផ្សារទេសចរណ៍ផ្ទៃក្នុង។

**ទី៤)-កត្តាចិត្តសាស្ត្រ÷** ក្នុងបរិការណ៍នេះ ការសម្រេចចិត្តរបស់ភ្ញៀវទេសចរផ្ទៃក្នុងចំពោះការជ្រើសរើសគោលដៅទេសចរណ៍ និងការធ្វើដំណើរកម្សាន្ត មានទំនោរគិតគូរខ្ពស់លើភាពស្អាត, អនាម័យ និងសុវត្ថិភាព ដែលនេះជាកត្តាសត្យានុម័ត យ៉ាងសំខាន់ក្នុងការជំរុញសកម្មភាពទេសចរណ៍។ ជារួម ការកសាងទំនុកចិត្ត និងភាពជឿជាក់ (Trust & Confidence) ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកស្ទួយ និងជំរុញចលនាទេសចរណ៍ផ្ទៃក្នុង។ ដូច្នេះ រាជរដ្ឋាភិបាលបានរៀបចំវិធានការគោលនយោបាយប្រកបដោយស្មារតីបុរេសកម្ម និងប្រុងប្រយ័ត្នខ្ពស់ ដល់ការជំរុញទេសចរណ៍ផ្ទៃក្នុង ជាពិសេស ដើម្បីដាក់ចេញនូវយុទ្ធនាការ **"ទស្សនាស្រុកយើង"** ក្រោមស្មារតី **"ស្រលាញ់ជាតិ ត្រូវស្គាល់ទឹកដី"**។

## ៣. វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង

ដើម្បីធានាឱ្យបាននូវភាពជោគជ័យក្នុងការជំរុញចលនាទេសចរណ៍ផ្ទៃក្នុង រាជរដ្ឋាភិបាលបានគិតគូររៀបចំដាក់ចេញវិធានការសំខាន់ៗ ដែលរួមមានទាំង វិធានការរដ្ឋបាល, វិធានការសុខាភិបាល, វិធានការពន្ធ និងវិធានការមិនមែនពន្ធ សំដៅសម្រេចឱ្យបាននូវគោលដៅសំខាន់ៗ **ចំនួន ៥** រួមមាន÷ **ទី១)**-ការលើកកម្ពស់ទំនុកចិត្ត និងភាពជឿជាក់របស់ភ្ញៀវទេសចរផ្ទៃក្នុង, **ទី២)**-ការជំរុញដំណើរការឡើងវិញរបស់អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍តាមគន្លងប្រក្រតីភាពថ្មី, **ទី៣)**-ការបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរផ្ទៃក្នុង, **ទី៤)**-ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍បម្រើឱ្យចលនាទេសចរណ៍ផ្ទៃក្នុង និង **ទី៥)**-ការផ្សព្វផ្សាយ ការអប់រំ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈ។

### ៣.១. ការលើកកម្ពស់ទំនុកចិត្ត និងភាពជឿជាក់របស់ភ្ញៀវទេសចរផ្ទៃក្នុង

ដោយសារហានិភ័យនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅបន្តមាន, ការជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនឹងមិនអាចសម្រេចជោគជ័យបានទេ ប្រសិនបើភ្ញៀវទេសចរនៅមិនទាន់មានទំនុកចិត្ត និងភាពជឿជាក់គ្រប់គ្រាន់។ អាស្រ័យហេតុនេះ, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញនូវវិធានការមួយចំនួន តាមរយៈការរៀបចំផែនការគ្រប់គ្រងគោលដៅទេសចរណ៍ក្នុងស្រុកដែលមានសុវត្ថិភាពនៅតាមបណ្តារាជធានី-ខេត្ត ដូចខាងក្រោម÷

- **(១). គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត** ត្រូវវាយតម្លៃគោលដៅទេសចរណ៍សុវត្ថិភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន(កម្រិតឃុំ-សង្កាត់ ឬក្រុង-ស្រុក-ខណ្ឌ ឬតាមគោលដៅទេសចរណ៍ទីមួយៗ) ដើម្បីជំរុញសកម្មភាពទេសចរណ៍ផ្ទៃក្នុង ដោយធ្វើការវាយតម្លៃផ្អែកលើសូចនាករសមិទ្ធកម្មចំនួន ៤ នៅតាមបណ្តារាជធានី-ខេត្តនៃដែនសមត្ថកិច្ចរបស់ខ្លួន÷ **ទី១)**-អត្រានៃការចាក់វ៉ាក់សាំងសំដៅបង្កើតភាពស៊ាំសហគមន៍, **ទី២)**-អត្រាអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និង

កម្រិតធ្ងន់ និងអត្រាស្លាប់នៃអ្នកជំងឺកូវីដ-១៩, **ទី៣)**-សមត្ថភាពនៃការឆ្លើយតប និងព្យាបាល និងការគ្រប់គ្រងហានិភ័យដែលអាចកើតមានពីមេរោគបំប្លែងថ្មី និង **ទី៤)**-ការត្រៀមខ្លួនរបស់ឧស្សាហកម្មទេសចរណ៍ ជាអាទិ៍ ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ និងការទទួលបានការចាក់វ៉ាក់សាំងគ្រប់ដូសសម្រាប់បុគ្គលិកបម្រើការងារក្នុងវិស័យទេសចរណ៍ទាំងអស់។ ផ្អែកលើវិធីសាស្ត្រនៃការវាយតម្លៃនេះ តំបន់ឬគោលដៅទេសចរណ៍សុវត្ថិភាពសម្រាប់សកម្មភាពទេសចរណ៍ផ្ទៃក្នុង នឹងត្រូវកំណត់ជា **៣ ប្រភេទ** រួមមាន ពណ៌បៃតង, ពណ៌លឿង និង ពណ៌ក្រហម។ ជារួម តំបន់ ឬគោលដៅទេសចរណ៍ដែលមានពណ៌បៃតង ជាតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព, តំបន់ ឬគោលដៅទេសចរណ៍ពណ៌លឿង ជាកន្លែងដែលមានហានិភ័យទាប, និងតំបន់ ឬគោលដៅទេសចរណ៍ពណ៌ក្រហម ជាកន្លែងដែលមានហានិភ័យខ្ពស់។ គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្តត្រូវអនុវត្ត **យន្តការបើក-បិទគោលដៅ (Switch On-Off Mechanism)** ដោយអនុញ្ញាតឱ្យបើកទទួលទេសចរណ៍ផ្ទៃក្នុងតែនៅក្នុងតំបន់ ឬគោលដៅទេសចរណ៍ក្នុងស្រុកពណ៌បៃតង និងលឿងប៉ុណ្ណោះ។

**(២).** ត្រូវរៀបចំ **"ពិធីសារសុវត្ថិភាពសម្រាប់ចលនាទេសចរណ៍ផ្ទៃក្នុង"** ដែលមានវិសាលភាពគ្របដណ្តប់លើរាល់ប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរ ដើម្បីគ្រប់គ្រងសកម្មភាពទេសចរណ៍នៅក្នុង **តំបន់ ឬគោលដៅទេសចរណ៍ក្នុងស្រុកបៃតង និងលឿង** ដោយមានការរៀបចំសៀវភៅណែនាំ ឬផ្លាកសញ្ញាដែលងាយយល់ និងងាយចងចាំ សម្រាប់ភ្ញៀវទេសចរផ្ទៃក្នុង អំពី **"ប្រការគួរធ្វើ និងមិនគួរធ្វើ" (Do & Don't)** នៅតាមតំបន់ ឬគោលដៅទេសចរណ៍សុវត្ថិភាព ព្រមទាំងផ្ទាំងរូបភាពណែនាំ ដែលមានច្រើនភាសា និងរៀបចំជា QR Code ដើម្បីឱ្យភ្ញៀវទេសចរអាចស្កេន និងទទួលបាននូវការណែនាំទាំងនោះក្នុងទូរស័ព្ទដៃរបស់ខ្លួន។

**(៣).** ត្រូវពង្រឹងការតាមដានត្រួតពិនិត្យការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដា (SOP), វិធានសុវត្ថិភាពទេសចរណ៍ (មានឡាបិល "*Label*" បញ្ជាក់) និងវិធានការណែនាំនានា ដែលដាក់ចេញដោយក្រសួងទេសចរណ៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ សម្រាប់ការធ្វើដំណើរនិងការដឹកជញ្ជូន និងនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍, វប្បធម៌ និងសិល្បៈ, វត្តអារាម និងទីតាំងសាសនា, និង ទីតាំងដទៃទៀតដែលមានឧបនិស្ស័យទាក់ទាញទេសចរណ៍ផ្ទៃក្នុង។

**(៤).** ត្រូវរៀបចំ **"ផែនទីឌីជីថល"** សម្រាប់តំបន់ ឬគោលដៅទេសចរណ៍ផ្ទៃក្នុងសុវត្ថិភាព ដើម្បីឱ្យភ្ញៀវទេសចរផ្ទៃក្នុងងាយស្រួលពិនិត្យ និងស្វែករកគោលដៅធ្វើដំណើរ។

**(៥).** អាជ្ញាធរមូលដ្ឋានត្រូវ÷ **ទី១)**-ពង្រឹងការអនុវត្ត និងលើកកម្ពស់អនុលោមភាពតាមវិធានការសុខាភិបាល, វិធានការរដ្ឋបាល, វិធានការច្បាប់, ការផ្សព្វផ្សាយ និងការអប់រំពាក់ព័ន្ធ, **ទី២)**-លើកកម្ពស់ និងពង្រឹងគុណភាពសេវាកម្ម និង **ទី៣)**-លើកកម្ពស់ និងពង្រឹងអនាម័យសាធារណៈ

ដូចជា ការរៀបចំទីតាំងលាងដៃ, បង្គន់អនាម័យសមស្រប និងមានការវាស់កម្ដៅ និងសម្អាតទីតាំងរមណីយដ្ឋានទេសចរណ៍ជាប្រចាំ។

**(៦).** តម្រូវឱ្យបុគ្គលិក, អាជីវករ និងអ្នកផ្តល់សេវាកម្មទេសចរណ៍ទាំងអស់ចាក់វ៉ាក់សាំងឱ្យបានគ្រប់គ្នាមុននឹងអាចចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន និងទិញស្តុកឧបករណ៍ធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩សម្រាប់ធ្វើតេស្តបុគ្គលិក ម្តង ក្នុង ១ (មួយ) ខែ ព្រមទាំងបញ្ចូលទិន្នន័យបុគ្គលិកដែលបានចាក់វ៉ាក់សាំងទៅក្នុង**ប្រព័ន្ធ Telegram BOT**។ ទន្ទឹមនេះ ត្រូវរៀបចំបង្កើត **ឡាបិល-Label "VACCINATED" នៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់** ដើម្បីផ្សព្វផ្សាយ និងបញ្ជាក់ថាបុគ្គលិកបម្រើការងារក្នុងនោះបានទទួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩រួចរាល់ ឬ បុគ្គលិកបម្រើការទាំងអស់ត្រូវពាក់ប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅពេលបំពេញការងារ។ ចំពោះភ្ញៀវទេសចរ ត្រូវបង្ហាញប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជាកាតព្វកិច្ច នៅពេលចូលមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់។

## ៣.២. ការជំរុញដំណើរការឡើងវិញរបស់អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍តាមគន្លងប្រក្រតីភាពថ្មី

អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍ជាតួអង្គយ៉ាងសំខាន់ក្នុងការជំរុញឱ្យវិស័យទេសចរណ៍ទាំងមូលងើបឡើងវិញជាបណ្តើរៗ។ ហានិភ័យនៃការផ្ទុះជំងឺកូវីដ-១៩ នៅតែបន្តជាកត្តាអវិជ្ជមានចំពោះផ្នែកអាជីវកម្ម និងផ្នែកសុខុមាលភាព ដែលអាចរារាំងឱ្យអាជីវកម្ម-ប្រតិបត្តិករទេសចរណ៍មួយចំនួនធំត្រូវបង្ខំចិត្តដកថយពីការចូលរួមក្នុងទីផ្សារទេសចរណ៍ឡើងវិញ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវវិធានការចាំបាច់ ដើម្បីជំរុញដំណើរការឡើងវិញរបស់អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍ ប្រកបដោយសុវត្ថិភាពតាមគន្លងប្រក្រតីភាពថ្មី ដូចខាងក្រោម៖

**(៧).** ដើម្បីជំរុញចលនាទេសចរណ៍ផ្ទៃក្នុងប្រកបដោយភាពជឿជាក់និងកក់ក្តៅ ត្រូវមានយន្តការតាមដាននិងវាយតម្លៃនូវរាល់ការអនុវត្ត, ការសម្របខ្លួន និងការកែប្រែគំរូអាជីវកម្ម-ប្រតិបត្តិករទេសចរណ៍ឱ្យស្របតាមគន្លងប្រក្រតីភាពថ្មីរបស់អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍ ដោយត្រូវអនុវត្តតាមវិធានសុវត្ថិភាពទេសចរណ៍ដែលមានជាធរមាន ជាពិសេសនីតិវិធីប្រតិបត្តិស្តង់ដា (SOP) តាមគន្លងប្រក្រតីភាពថ្មី សម្រាប់មូលដ្ឋានអាជីវកម្ម និងគោលដៅទេសចរណ៍ឱ្យបានតឹងរ៉ឹង ប្រកបដោយការទទួលខុសត្រូវ និងយកចិត្តទុកដាក់ខ្ពស់បំផុត ព្រមទាំងមានការធ្វើអធិការកិច្ចជាប្រចាំ ដោយមានសមាសភាពចូលរួមពីរដ្ឋបាលរាជធានី-ខេត្ត និងស្ថាប័នពាក់ព័ន្ធនានា។ ជាពិសេស កំណត់ចំនួនមនុស្សដែលអាចប្រមូលផ្តុំបាន សម្រាប់សកម្មភាពទេសចរណ៍នានា ទៅតាមប្រភេទសកម្មភាព, ទីតាំង និងស្ថានភាពនៃការឆ្លង ដូចជាការកំណត់ឱ្យភោជនីយដ្ឋាន, សណ្ឋាគារ និងរមណីយដ្ឋាន អាចទទួលអតិថិជននៅក្នុងកម្រិតអតិបរមាណាមួយ ជាដើម។

**(៨).** សម្រួលលក្ខខណ្ឌអំណោយផលមួយចំនួន សម្រាប់ជំរុញដំណើរការឡើងវិញរបស់អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍ ក្នុងនោះ÷ **ទី១)-**អនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកំណត់អំពីការគ្រប់គ្រងការប្រើប្រាស់គ្រឿងស្រវឹងនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ ដោយក្រសួងទេសចរណ៍ត្រូវរៀបចំការណែនាំ នៅក្នុងបរិបទនៃវិបត្តិជំងឺកូវីដ-១៩ និង **ទី២)-** ការគ្រប់គ្រងដំណើរការមូលដ្ឋានអាជីវកម្មទេសចរណ៍ ត្រូវស្របតាមស្មារតីនៃ**ផែនការយុទ្ធសាស្ត្ររស់នៅតាមគន្លងប្រក្រតីភាពថ្មី**។

**(៩).** បន្តអនុវត្តការគាំទ្រហិរញ្ញប្បទានលើកទឹកចិត្ត និងសិក្សារៀបចំវិធានការទ្រទ្រង់ថ្មីៗ ជាពិសេសសម្រាប់តំបន់ប៉ូលទេសចរណ៍ ឬគោលដៅទេសចរណ៍ ដែលអនុញ្ញាតឱ្យមានសកម្មភាពពេញ-លេញឡើងវិញ តាមរយៈ÷ **ទី១)-**បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ ចំពោះសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ក្រុងបាវិត និងក្រុងប៉ោយប៉ែត សម្រាប់រយៈពេល **៦ខែបន្ថែមទៀត ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២។** អាជីវកម្មទាំងនេះ នៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និងប្រើប្រាស់ប្រព័ន្ធអនឡាញ សម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម (E-VAT) ជារៀងរាល់ខែ ក្នុងអំឡុងពេលនៃការលើកលែងនេះ, **ទី២)-**បន្តលើកលែងការបង់ពន្ធអប្បបរមា (Minimum Tax) សម្រាប់រយៈពេល **០៦ ខែបន្ថែមទៀត ពីខែមករា ដល់ខែមិថុនា ឆ្នាំ ២០២២** ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ ដែលបានចុះបញ្ជីនៅកម្ពុជា, **ទី៣)-**បន្តផ្តល់ការអនុគ្រោះចំពោះការបង់ប្រាក់ពិន័យលើកម្រៃអាកាសចរស៊ីវិល ដោយពន្យារពេល **០៦ ខែបន្ថែមទៀត ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២**, **ទី៤)-**ពង្រីកគម្រោងសាច់ប្រាក់ពលកម្ម សម្រាប់ការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធតូចៗ បម្រើឱ្យវិស័យទេសចរណ៍ និង **ទី៥)-**អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្របសម្រួលជាមួយសមាគមធនាគារ និងតួអង្គដែលមានការពាក់ព័ន្ធ ដើម្បីរៀបចំគម្រោងសហហិរញ្ញប្បទាន (Co-Financing Scheme)។

**(១០).** រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពជំនាញទេសចរណ៍ ជាពិសេសវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថល (Digital Literacy) ក្នុងវិស័យទេសចរណ៍ និងជំនាញឌីជីថលកម្រិតមូលដ្ឋាន ឆ្លើយតបនឹងតម្រូវការតាមគន្លងប្រក្រតីភាពថ្មី និងបដិវត្តន៍ឧស្សាហកម្ម ៤.០ ជាអាទិ៍ជំនាញធ្វើយុទ្ធសាស្ត្រទីផ្សារតាមប្រព័ន្ធអនឡាញ ឬតាមបណ្តាញសង្គម ជាដើម ដោយប្រើប្រាស់កញ្ចប់ថវិការបស់ **"មូលនិធិអភិវឌ្ឍន៍ជំនាញ"** (Skill Development Fund-SDF) និងសិក្សាលទ្ធភាពបើកសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ឱ្យដំណើរការឡើងវិញ។

**(១១).** ជំរុញឱ្យមានការទទួលយក និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យបានទូលំទូលាយ ជាពិសេសសម្រាប់ការផ្សព្វផ្សាយ, ការកក់កញ្ចប់ទេសចរណ៍, ការផ្ដល់មតិយោបល់ត្រលប់ (Feedback) លើសេវាទេសចរណ៍ ក៏ដូចជាការបង្កើតឱ្យមានជម្រើសទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក នៅគ្រប់ទីកន្លែង និងតំបន់ទេសចរណ៍នានា តាមរយៈការប្រើប្រាស់ QR Code និង/ឬ ការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារជាដើម។ ជាមួយគ្នានេះផងដែរ លើកទឹកចិត្តម្ចាស់អាជីវកម្មទេសចរណ៍នានា ឱ្យមានភាពបត់បែនខ្ពស់ក្នុងការរៀបចំកក់សំបុត្រ និងរៀបចំកម្មវិធីទេសចរណ៍ជូនអតិថិជន ដើម្បីបង្កភាពងាយស្រួលជាងមុនក្នុងការផ្លាស់ប្ដូរពេលវេលាកក់ និងការបញ្ឈប់ការកក់ ។ល។ និង ។ល។

**(១២).** ធ្វើទំនើបនីយកម្មមធ្យោបាយផ្ដល់ព័ត៌មានទេសចរណ៍ផ្ទៃក្នុង ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ពិសេសទំនើបនីយកម្មមណ្ឌលព័ត៌មានទេសចរណ៍នៅតាមរាជធានី-ខេត្ត តាមរយៈគម្រោងវិនិយោគសាធារណៈ។

## ៣.៣. ការបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរផ្ទៃក្នុង

ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានបណ្ដាលឱ្យប្រតិបត្តិការមួយចំនួនក្នុងសកម្មភាពទេសចរណ៍ និងសកម្មភាពផ្សេងៗទៀត មានការកែប្រែ ព្រមទាំងបាន និងកំពុងបង្កការលំបាក និងជាកត្តារាំងស្ទះដល់ចលនាទេសចរណ៍ផ្ទៃក្នុង។ ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរជាតិ និងភ្ញៀវទេសចរបរទេសដែលមានបំណងធ្វើដំណើរទេសចរណ៍ផ្ទៃក្នុង ដូចខាងក្រោម÷

### ៣.៣.១. ការបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរជាតិធ្វើដំណើរទេសចរណ៍ផ្ទៃក្នុង

**(១៣).** សិក្សាបង្កើតប័ណ្ណបញ្ចុះតម្លៃថ្នាក់ជាតិ ផ្សារភ្ជាប់ជាមួយប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ របស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការ ក្រោមពាក្យស្លោក **"ខ្ញុំបានចាក់វ៉ាក់សាំង ខ្ញុំទទួលបានការបញ្ចុះតម្លៃ"** ដែលអនុវត្តចំពោះភ្ញៀវទេសចរដែលបានចាក់វ៉ាក់សាំង នឹងទទួលបានការបញ្ចុះតម្លៃ ឬការលើកទឹកចិត្តដល់ការធ្វើដំណើរទេសចរណ៍ផ្ទៃក្នុង ដូចជា សេវាកម្មស្នាក់នៅ, សំបុត្រចូលរមណីយដ្ឋាន, ភោជនីយដ្ឋាន ជាដើម ដោយជំរុញឱ្យមានការចូលរួមពីវិស័យឯកជនឈរលើគោលការណ៍ស្ម័គ្រចិត្តឱ្យបានទូលំទូលាយ។

**(១៤).** ជំរុញការរៀបចំ**កញ្ចប់ទេសចរណ៍បែប "Staycation"** នៅតាមសណ្ឋាគារលំដាប់ផ្កាយ៤ ឬផ្កាយ៥ ឬរីស៊ត (Resort) សម្រាប់ភ្ញៀវទេសចរលក្ខណៈគ្រួសារ ដែលរួមមានសេវាកម្មដឹកជញ្ជូនដល់ផ្ទះ (Pick up), ការរៀបចំបន្ទប់ Suite, ការបញ្ចុះតម្លៃទៅលើអាហារ និងភេសជ្ជៈ ផ្សារភ្ជាប់ជាមួយការផ្ដល់ជូនសេវាកម្មផ្សេងៗទៀត ប្រកបដោយគុណភាព និងថ្លៃសមរម្យ។

**(១៥).** រៀបចំកញ្ចប់ទស្សនកិច្ចសម្រាប់សិស្ស-និស្សិត, សាស្ត្រាចារ្យ, មន្ត្រីរាជការ និងកម្មករ-កម្មការនីមកកាន់រាជធានីភ្នំពេញ *(កីឡដ្ឋានមរតកតេជោ, វិមានឈ្នះ-ឈ្នះ...)*, ខេត្តព្រះសីហនុ *(ផ្សារភ្ជាប់នឹងការកសាងផ្លូវ ៣៤ខ្សែ)*, ខេត្តសៀមរាប-អង្គរ *(ផ្សារភ្ជាប់នឹងការកសាងផ្លូវ ៣៨ខ្សែ)*, ក្នុងឧទ្យានជាតិ, កម្មវិធីទេសចរណ៍រថភ្លើង, កម្មវិធីទេសចរណ៍ជុំវិញបឹងទន្លេសាប និងកញ្ចប់ទស្សនកិច្ចទៅកាន់គោលដៅទេសចរណ៍សំខាន់ៗផ្សេងទៀត ដោយបង្កើត**បណ្ណដំណើរកម្សាន្តផ្ទៃក្នុង (Domestic Holiday Voucher)** ដែលមានការបញ្ចុះតម្លៃ ជាមួយកិច្ចសហការពីវិស័យឯកជន ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋឱ្យធ្វើដំណើរកម្សាន្តនៅក្នុងប្រទេស។

**(១៦).** បង្កលក្ខណៈងាយស្រួលដល់ប្រភេទទេសចរណ៍ដោយការបើកបរដោយខ្លួនឯង (Drive Tourism)[1] តាមរយៈ÷ **ទី១)-**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវតភ្ជាប់ទៅកាន់រមណីយដ្ឋានទេសចរណ៍ដែលមានប្រជាប្រិយភាពនៅតាមរាជធានី-ខេត្ត និងត្រូវប្រើប្រាស់យន្តការភាពជាដៃគូរដ្ឋ-ឯកជនក្នុងការវិនិយោគរៀបចំស្ថានីយចំណតតាមដងផ្លូវ (Road Station) នៅតាមតំបន់ទេសចរណ៍អាទិភាព, **ទី២)-**កាត់បន្ថយការផ្សាយពាណិជ្ជកម្មស្រាបៀរពីតាមដងផ្លូវសំខាន់ៗនៅតំបន់ទេសចរណ៍ និងជិន្ទូសមកវិញនូវរូបភាពស្អាតៗនៃតំបន់ទេសចរណ៍, **ទី៣)-**បំពាក់ស្លាកសញ្ញាបង្ហាញផ្លូវ សម្រាប់ភ្ញៀវទេសចរជាតិ, **ទី៤)-**បន្តពង្រឹងសុវត្ថិភាពចរាចរណ៍ តាមរយៈការត្រួតពិនិត្យបច្ចេកទេស គោរពតាមស្តង់ដាដឹកជញ្ជូន និងផ្លូវថ្នល់មានស្តង់ដាសុវត្ថិភាព, **ទី៥)-**ពង្រឹងផែនការគ្រប់គ្រងចរាចរណ៍នៅតាមគោលដៅទេសចរណ៍ ដោយត្រូវពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ឱ្យបានត្រឹមត្រូវ និងត្រូវមានការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងខ្លឹមសារនៃការអនុវត្តច្បាប់ចរាចរណ៍ដល់ភ្ញៀវទេសចរ និងជំរុញកែលម្អចំណតរថយន្តនៅតាមបណ្ដារាជធានី-ខេត្ត និង **ទី៦)-**បង្កើតកម្មវិធីទូរស័ព្ទដៃ បង្ហាញព័ត៌មាននៃការធ្វើដំណើរសម្រាប់ភ្ញៀវទេសចរភ្ជាប់ទៅនឹងគោលដៅទេសចរណ៍សំខាន់ៗផ្សារភ្ជាប់នឹងប្រព័ន្ធ GPS ឬ Google Map ដោយជំរុញឱ្យអាជីវករចុះឈ្មោះអាជីវកម្មរបស់ខ្លួនក្នុង Google Map និងលើកទឹកចិត្តឱ្យអាជីវកម្មទាំងនោះបញ្ចូលព័ត៌មានទីតាំងទេសចរណ៍តាមមូលដ្ឋានរបស់ខ្លួន ក្នុងថ្នាលព័ត៌មានទេសចរណ៍ផ្សេងៗ។

**(១៧).** ជំរុញការហោះហើរក្នុងស្រុក និងការធ្វើដំណើរទេសចរណ៍តាមផ្លូវទឹក ដើម្បីបង្កើនការតភ្ជាប់ទៅកាន់គោលដៅទេសចរណ៍នានានៅទូទាំងប្រទេស។

---

[1] **ទេសចរណ៍ដោយការបើកបរដោយខ្លួនឯង** គឺជាការអនុវត្តទម្រង់មួយនៃទេសចរណ៍ផ្ទៃក្នុង ដោយក្នុងនោះភ្ញៀវទេសចរប្រើប្រាស់នូវយានយន្តក្នុងការធ្វើដំណើរទៅកាន់គោលដៅទេសចរណ៍ ក្នុងគោលបំណងសម្រាកលម្ហែ ឬទៅសួរសុខទុក្ខមិត្តភ័ក្តិ និងក្រុមគ្រួសារសាច់ញាតិដោយអាចជាការធ្វើដំណើរវិលល្ងាច ឬស្នាក់នៅក្នុងគោលដៅទេសចរណ៍លើសពីមួយយប់។

### ៣.៣.២. បន្ធូរបន្ថយលក្ខខណ្ឌ: ងាយស្រួលដល់ភ្ញៀវទេសចរបរទេសធ្វើដំណើរទេសចរណ៍ផ្ទៃក្នុង

**(១៨).** ត្រូវមានការលើកទឹកចិត្ត និងជំរុញឱ្យមានដំណើរកម្សាន្ត តាមរយៈការរៀបចំ**ប័ណ្ណទស្សនា រមណីយដ្ឋានបេតិកភណ្ឌពិភពលោក (ប្រាសាទអង្គរវត្ត, ប្រាសាទព្រះវិហារ និងប្រាសាទសំបូរព្រៃគុក)** និងរមណីយដ្ឋានទេសចរណ៍សំខាន់ៗផ្សេងទៀតដោយអាចឱ្យភ្ញៀវទេសចរបរទេសផ្ទៃក្នុងទស្សនាបានច្រើនដង ក្នុងតម្លៃសមរម្យ។

**(១៩).** សិក្សាលទ្ធភាពក្នុងការបង្កើនភាពទាក់ទាញ ដោយផ្តល់ជម្រើសបន្ថែមនៃប្រភេទសំបុត្រចូលទស្សនារមណីយដ្ឋានបេតិកភណ្ឌអង្គរសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង ដោយបន្តសុពលភាពសេចក្តីជូនដំណឹង ស្តីពីការអនុវត្តគោលនយោបាយលើកទឹកចិត្តនៃការលក់ប័ណ្ណចូលទស្សនារមណីយដ្ឋានអង្គរ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២២។

### ៣.៤. ការអភិវឌ្ឍផលិតផលទេសចរណ៍បម្រើឱ្យចលនាទេសចរណ៍ផ្ទៃក្នុង

ដោយឈរលើស្មារតីនៃការបំប្លែងបរិបទជំងឺកូវីដ-១៩ ជាកាលានុវត្តភាព សម្រាប់ការលើកកម្ពស់វិស័យទេសចរណ៍ទាំងមូល រាជរដ្ឋាភិបាលនឹងបន្តខិតខំពង្រឹង និងពង្រីកទីផ្សារទេសចរណ៍ និងផ្តល់ជូនភ្ញៀវទេសចរនូវបទពិសោធន៍ទេសចរណ៍ប្លែកៗ តាមរយៈការបន្តខិតខំរៀបចំ និងក៏ដូចជាការផ្តល់ការគាំទ្រដល់ការវិនិយោគឯកជន សំដៅបង្កើននូវផលិតផលទេសចរណ៍ថ្មីៗ ទាក់ទាញចលនាទេសចរណ៍ផ្ទៃក្នុងនៅតាមប៉ូលសំខាន់ៗ ដូចជា÷

**(២០). រាជធានីភ្នំពេញ និងតំបន់ជុំវិញ** ត្រូវធ្វើពិពិធកម្មផលិតផលទេសចរណ៍ ដោយរៀបចំឱ្យមានតំបន់ទេសចរណ៍ថ្មើរជើង ការកម្សាន្តតាមនាវាទេសចរណ៍ និងបង្កើតកញ្ចប់ទស្សនកិច្ចទេសចរណ៍ក្នុងស្រុកភ្ជាប់នឹងតំបន់ជុំវិញនៃរាជធានីភ្នំពេញ ដូចជានៅរមណីយដ្ឋានតេទឹកពុះ, រមណីយដ្ឋានឧដុង្គ, កោះដាច់ និងភូមិចម្លាក់ប្រាក់នៅកំពង់ហ្លួង ជាដើម។

**(២១). ខេត្តសៀមរាប-អង្គរ និងតំបន់ជុំវិញ** ត្រូវរៀបចំ និងជំរុញឱ្យមានការវិនិយោគក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗ និងតាមតំបន់ទេសចរណ៍អាទិភាពទាំង៦ **"សៀមរាប÷ ក្រៅពីប្រាសាទ"** ដោយផ្សារភ្ជាប់រវាងសម្បត្តិធនធានវប្បធម៌, ប្រវត្តិសាស្ត្រ និងសម្បត្តិធនធានធម្មជាតិ អមជាមួយសកម្មភាពទេសចរណ៍ធម្មជាតិ, ទេសចរណ៍ផ្សងព្រេង និងកីឡាទេសចរណ៍ ដូចជា កីឡាជិះកង់កម្សាន្តគយគន់ទេសភាព និងយូហ្គា (Yoga)។ល។ ទន្ទឹមនេះ ជាមួយគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវ ៣៨ខ្សែ ក្នុងក្រុងសៀមរាប អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំតំបន់ថ្មើរជើងក្នុងក្រុងសៀមរាប។ នៅតំបន់បឹងទន្លេសាបត្រូវរៀបចំកែលម្អកំពង់ផែ

ទេសចរណ៍ចុងឃ្នាស ដោយជំរុញការអនុវត្ត **ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២១-២០៣៥**។

**(២២). តំបន់ឆ្នេរសមុទ្រកម្ពុជា** ដោយសារសមិទ្ធផលនៃការសាងសង់ផ្លូវចំនួន៣៤ខ្សែបានបិទបញ្ចប់រួចរាល់ ខេត្តព្រះសីហនុមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវដ៏ល្អប្រសើរ ជាមេដែកទាក់ទាញភ្ញៀវទេសចរផ្ទៃក្នុងមកកាន់ខេត្តព្រះសីហនុ និងជាសក្តានុពលសម្រាប់រៀបចំជា**របៀងទេសចរណ៍ភាគខាងត្បូង** តភ្ជាប់ខេត្តតំបន់ឆ្នេរ ជាមួយបណ្តាកោះដ៏ប្រណិតៗនានា ដូចជា កោះរ៉ុង, កោះរ៉ុងសន្លឹម, កោះសង្ឃារ និងតំបន់ទេសចរណ៍មានសក្តានុពលដ៏សម្បូរបែបផ្សេងទៀត ដូចជា គោលដៅទេសចរណ៍រាម តារាសាគរ ខេត្តកំពត និងខេត្តកែប ដែលរាជរដ្ឋាភិបាលកំពុងបញ្ចប់ការរៀបចំ**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តកែប ឆ្នាំ២០២២-២០៣៥**។

**(២៣). តំបន់ភូមិភាគឦសាន្ត** ត្រូវបន្តជំរុញចលនាទេសចរណ៍ផ្ទៃក្នុង និងសកម្មភាពដំណើរកម្សាន្តបែបធម្មជាតិនៅក្នុងតំបន់នោះ ពិសេសទៅកាន់ខេត្តមណ្ឌលគិរី ដោយត្រូវជំរុញការអនុវត្ត **ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ២០២១-២០៣៥**។

**(២៤). តំបន់តាមដងទន្លេមេគង្គ និងទន្លេបាសាក់** ត្រូវរៀបចំឱ្យមានភូមិទេសចរណ៍ ដើម្បីផ្តល់សេវាកម្មស្នាក់នៅសម្រាប់ភ្ញៀវទេសចរនៅតាមផ្ទះប្រជាជន ដែលរស់នៅតាមទីក្រុង, ទីប្រជុំជន និងនៅតាមដងទន្លេ និងត្រូវសិក្សារៀបចំឱ្យមានកំពង់ផែទេសចរណ៍ នៅតាមដងទន្លេមេគង្គ និងទន្លេសាបបន្ថែមទៀត។

ក្រៅពីការអភិវឌ្ឍទេសចរណ៍តាមតំបន់អាទិភាព កម្ពុជានឹងរៀបចំបង្កើតផលិតផលទេសចរណ៍ថ្មីៗ នៅក្នុងក្របខណ្ឌទូទាំងប្រទេស ដូចខាងក្រោម÷

**(២៥).** បន្តជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដែលរួមមាន ដូចជា ផ្លូវ, អគ្គិសនី និងទឹក ជាដើម ពិសេសផ្លូវតភ្ជាប់នៅតំបន់ទេសចរណ៍ថ្មីៗ និងមានសក្តានុពល។

**(២៦).** ដាក់ចេញយុទ្ធនាការជំរុញទេសចរណ៍ម្ហូបអាហារ ដោយគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត ត្រូវជំរុញយុទ្ធនាការ **"ខេត្តមួយ ម្ហូបអាហារអត្តសញ្ញាណមួយយ៉ាងតិច"**, យុទ្ធនាការ **"ខេត្តមួយ វិថីម្ហូបអាហារមួយ"** និងយុទ្ធនាការជំរុញចលនាទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ ដោយត្រូវជំរុញសកម្មភាពដាំដើមឈើ និងលើកទឹកចិត្តឱ្យមាន **"ខេត្តមួយ សួនទេសចរណ៍មួយ"**។

**(២៧).** ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជនត្រូវចូលរួមជំរុញចលនាទេសចរណ៍ផ្ទៃក្នុង តាមរយៈការរៀបចំកិច្ចប្រជុំនៅតាមរាជធានី-ខេត្ត ក្រោមទម្រង់ជាលក្ខណៈកូនកាត់ (ដោយមានអ្នក

ចូលរួមផ្ទាល់ក្នុងកម្រិតសមល្មមអមដោយការផ្សាយ និងចូលរួមតាមប្រព័ន្ធវីដេអូ) នៅពេលស្ថានភាពគ្រប់គ្រងជំងឺកូវីដ-១៩ កាន់តែល្អប្រសើរ។

**(២៨).** ជំរុញចលនាទេសចរណ៍ផ្ទៃក្នុងផ្សារភ្ជាប់នឹងសកម្មភាពកសិ-ទេសចរណ៍, អេកូទេសចរណ៍, សហគមន៍ទេសចរណ៍ក្នុងស្រុក និងទេសចរណ៍ជនបទ, និងត្រូវខិតខំអភិវឌ្ឍន៍ចលនាទេសចរណ៍ផ្ទៃក្នុងផ្សារភ្ជាប់នឹងទស្សនទាននៃការអភិវឌ្ឍប្រកបដោយបរិយាបន្ន ដោយត្រូវខិតខំរៀបចំឱ្យមានផ្ទះស្នាក់តាមសហគមន៍នៅទីជនបទ និងការផលិតវត្ថុអនុស្សាវរីយ៍ក្នុងស្រុក។ ដើម្បីជំរុញការបង្កើតផលិតផលខ្មែរបម្រើឱ្យវិស័យទេសចរណ៍ រាជរដ្ឋាភិបាលនឹងប្រើប្រាស់ "មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព" សម្រាប់ផ្តល់ការគាំទ្រដល់គម្រោងគំរូខ្នាតតូចបម្រើដល់ខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងវិស័យទេសចរណ៍។

**(២៩).** អភិវឌ្ឍន៍គោលដៅទេសចរណ៍ស្អាត និងលើកកម្ពស់សោភ័ណភាពឡើងវិញនៅតាមគោលដៅទេសចរណ៍មួយចំនួន តាមរយៈការជំរុញចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"** ឱ្យបានកាន់តែទូលំទូលាយ នៅតាមគោលដៅទេសចរណ៍សំខាន់ៗសំដៅធានាឱ្យបានភាពស្អាត, អនាម័យ និងបរិស្ថានល្អ ក្នុងនោះ **"រមណីយដ្ឋានត្រូវស្អាត គ្មានសំរាមថង់ប្លាស្ទិកនៅរាយប៉ាយ"**, បង្គន់អនាម័យសាធារណៈត្រូវស្អាត និងត្រូវជំរុញយុទ្ធនាការ **"ភោជនីយដ្ឋានស្អាត គ្មានសំរាមថង់ប្លាស្ទិកក្រោមតុ"**, ជំរុញការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"**, និងរៀបចំទីតាំងសំខាន់ៗដែលមានឧបនិស្ស័យក្នុងការទាក់ទាញទេសចរណ៍ ឱ្យគោរពតាមនីតិវិធីប្រតិបត្តិស្តង់ដា (SOP) នៃគន្លងប្រក្រតីភាពថ្មី ជាអាទិ៍ អាហារដ្ឋាន, ផ្សារសាធារណៈ, ផ្សារទំនើប, រោងភាពយន្ត, សារមន្ទីរ, វត្តអារាម, ទីតាំងសាសនា, ចំណតរថយន្តក្រុង និងព្រលានយន្តហោះ ជាដើម។

### ៣.៥. ការផ្សព្វផ្សាយ ការអប់រំ និងការបញ្ជ្រាបការយល់ដឹងជាសាធារណៈ

បន្ថែមពីលើវិធានការខាងលើ វិធានការផ្សព្វផ្សាយ អប់រំ និងការបញ្ជ្រាបការយល់ដឹងជាសាធារណៈ គឺជាសមាសភាគដ៏សំខាន់ និងចាំបាច់ ក្នុងការជំរុញគ្រប់ភាគីពាក់ព័ន្ធនៅក្នុងវិស័យ និងសកម្មភាពទេសចរណ៍ ឱ្យចូលរួមយ៉ាងសកម្ម ក្នុងគោលដៅលើកកម្ពស់វិស័យ និងសកម្មភាពទេសចរណ៍ ដោយមានការធានាសុវត្ថិភាព និងសុខុមាលភាពដល់សហគមន៍ទាំងមូល។ ដើម្បីសម្រេចបាននូវគោលដៅនេះ រាជរដ្ឋាភិបាលនឹងអនុវត្តនូវវិធានការដូចខាងក្រោម÷

**(៣០).** ផ្សព្វផ្សាយ ដោយចេញជាសេចក្តីប្រកាសស្តីអំពីជំហររបស់រាជរដ្ឋាភិបាលជាក់លាក់ ក្នុងការជំរុញ និងលើកទឹកចិត្តទេសចរណ៍ក្នុងស្រុក និងសុវត្ថិភាពធ្វើដំណើរ សម្រាប់គោលដៅ

ទេសចរណ៍ និងសេវាកម្មទេសចរណ៍ ដែលមានសក្តានុពលខ្ពស់ និងមានហានិភ័យទាប ជូនប្រជាពលរដ្ឋ រួមជាមួយនឹងពេលវេលាច្បាស់លាស់ ដោយរៀបចំថ្នាលទំនាក់ទំនងសាធារណៈ (Public Communication Platform - អាចជា Website ឬ ទំព័រក្នុងបណ្តាញសង្គម) ដែលមានភាពច្បាស់លាស់, តម្លាភាព, ងាយយល់ និងមានការធ្វើបច្ចុប្បន្នកម្មទៀងទាត់ សម្រាប់ធ្វើការផ្សព្វផ្សាយអំពីកម្រិតហានិភ័យ និងវិធានការរដ្ឋបាល/សុខាភិបាល នៅតំបន់គោលដៅទេសចរណ៍នានា។

**(៣១).** ដាក់ចេញយុទ្ធសាស្ត្រលើកកម្ពស់ការយល់ដឹងជាសាធារណៈ នៅក្នុងក្របខណ្ឌនៃយុទ្ធនាការ **"ទស្សនាស្រុកយើង"** ក្រោមស្មារតី **"ស្រលាញ់ជាតិ ត្រូវស្គាល់ទឹកដី"** តាមរយៈការដាក់ចេញនូវ **យន្តការផ្សព្វផ្សាយ, ការអប់រំ និងការបញ្ជ្រាបការយល់ដឹងជាសាធារណៈចម្រុះ** ដូចខាងក្រោម ÷

- **ទី១)-កិច្ចសម្ភាសន៍÷** បង្កើតនូវបទសម្ភាសន៍ ជាមួយបុគ្គលសំខាន់ៗនៅក្នុងវិស័យទេសចរណ៍ ដូចជា ថ្នាក់ដឹកនាំ, មន្ត្រី, អ្នកជំនាញ, ប្រតិបត្តិករទេសចរណ៍ និងភាគីពាក់ព័ន្ធដែលមកពីវិស័យរដ្ឋ និងឯកជន ដែលទទួលបានភាពជោគជ័យនៅក្នុងអាជីវកម្មទេសចរណ៍ នៅក្នុងកម្មវិធីទូរទស្សន៍និងវិទ្យុល្បីៗជាប្រចាំ ដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្វែងយល់ និងចូលរួមចំណែកនៅក្នុងសកម្មភាពអភិវឌ្ឍវិស័យទេសចរណ៍។
- **ទី២)-ការរំលេចសាច់រឿង (Feature Stories)÷** ដើម្បីបង្កើនចំណាប់អារម្មណ៍របស់សាធារណជននៅក្នុងការធ្វើដំណើរកម្សាន្តផ្ទៃក្នុង ដោយត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចជា **ទី១)**-ត្រូវលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ឱ្យមានការសរសេរជាអត្ថបទរំលេចអំពីប្រភេទទេសចរណ៍ ដែលទាក់ទាញចំណាប់អារម្មណ៍ និងការចូលរួមពីអ្នកអាន និង **ទី២)**-ការបញ្ចូលរូបភាពនៃគោលដៅទេសចរណ៍ស្អាតៗក្នុងការផលិតបទចម្រៀង និងខ្សែភាពយន្ត ជាដើម។
- **ទី៣)**-ផលិតវីដេអូទេសចរណ៍ដែលមានសក្តានុពល នៅតាមគោលដៅទេសចរណ៍រាជធានី-ខេត្ត និងចម្រៀងទេសចរណ៍ ដើម្បីចាក់ផ្សាយតាមបណ្តាញស្ថានីយទូរទស្សន៍ និងប្រព័ន្ធបណ្តាញសង្គមនានា។
- និង **ទី៤)**-ជំរុញការផ្សព្វផ្សាយ,ការអប់រំនិងបញ្ជ្រាបការយល់ដឹងជាសាធារណៈ អំពីវិស័យទេសចរណ៍តាមរយៈបុគ្គលដែលមានឥទ្ធិពល (Influencers) នៅលើប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម (YouTube, Facebook, Tiktok, Instagram..) និងអ្នកផលិតរូបភាពនិងវីដេអូជំនាញ។ ទន្ទឹមនេះត្រូវមានការជំរុញ និងលើកទឹកចិត្តដល់ការផ្សព្វផ្សាយ និង

ផលិតរូបភាពវីដេអូ និងមាតិកាទេសចរណ៍នានា ដោយរាជរដ្ឋាភិបាលគួរសិក្សាដាក់ចេញគោលនយោបាយលើកទឹកចិត្តសម្រាប់បុគ្គលទាំងនោះ។

**(៣២).** រៀបចំ និងផ្សព្វផ្សាយព្រឹត្តិការណ៍សំខាន់ៗ ដូចជា បុណ្យសមុទ្រ នៅឆ្នាំ២០២២ និងឆ្នាំ២០២៣ និងបុណ្យទន្លេ, ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត, សង្ក្រាន្តរាជធានី-ខេត្ត នៅឆ្នាំ២០២៣ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមគន្លងប្រក្រតីភាពថ្មី និងត្រូវរៀបចំឱ្យមានសកម្មភាពកីឡាគ្រប់ទម្រង់ដែលអាចរៀបចំបានតាមលទ្ធភាពរបស់រដ្ឋបាលរាជធានី-ខេត្ត សំដៅត្រៀមឆ្ពោះទៅការធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំ**ព្រឹត្តិការណ៍ស៊ីហ្គេម ឆ្នាំ២០២៣ (SEA Games 2023)**។

**(៣៣). គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត** ត្រូវសិក្សាជំរុញព្រឹត្តិការណ៍ទេសចរណ៍ខ្នាតតូច ឬមធ្យម នៅក្នុងរាជធានី-ខេត្តរបស់ខ្លួន ជាពិសេសព្រឹត្តិការណ៍ ដែលមានលក្ខណៈឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រ វប្បធម៌ប្រពៃណីក្នុងតំបន់ តាមរាជធានី-ខេត្តរៀងៗខ្លួន ដើម្បីចូលរួមក្នុងការទាក់ទាញរំហូរនៃចលនាទេសចរណ៍ផ្ទៃក្នុង។

**(៣៤).** រៀបចំមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងស្រុកឱ្យមាននៅតាមរាជធានី-ខេត្តដែលមានសក្តានុពលទេសចរណ៍។

**(៣៥).** ពង្រឹង និងពង្រីកការចាប់យកបច្ចេកវិទ្យា ការប្រើប្រាស់ថ្នាលឌីជីថល (គេហទំព័រ Visit Cambodia, ប្រព័ន្ធបណ្តាញ (Facebook, Instagram, YouTube...) សម្រាប់ការផ្សព្វផ្សាយវិស័យទេសចរណ៍ផ្ទៃក្នុង។ លើសពីនេះទៀត នៅតាមគោលដៅទេសចរណ៍ធំៗ ត្រូវជំរុញការផ្សព្វផ្សាយ និងប្រើប្រាស់ការបកស្រាយពន្យល់តាមកម្មវិធីទូរស័ព្ទ ឬបច្ចេកវិទ្យា Augmented Reality (AR) ដើម្បីពន្យល់ និងបកស្រាយដល់ភ្ញៀវទេសចរផ្ទៃក្នុង។

## ៤. យន្តការអនុវត្ត

### ៤.១. យន្តការស្ថាប័ន

ការអនុវត្ត **"វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣"** នេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ គឺអាស្រ័យលើការប្តេជ្ញាចិត្ត និងការចូលរួមពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធគ្រប់ជាន់ថ្នាក់, អាជ្ញាធរមូលដ្ឋាន, កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋ ក្នុងការអនុវត្ត ស្របតាមតួនាទី, ភារកិច្ច និង ការទទួលខុសត្រូវរៀងៗខ្លួន។ ក្នុងន័យនេះ ការអនុវត្តការងារទាំងនេះ ទាមទារនូវការសហការស្អិតរមួត និងចូលរួមពីសំណាក់ក្រសួង-ស្ថាប័ន, ការរៀបចំឱ្យមានការត្រួតពិនិត្យលទ្ធផលអនុវត្តជាប្រចាំ, ការរៀបចំឱ្យមានការពិភាក្សាគ្នាយ៉ាងសកម្មដើម្បីជំរុញការងារ និងបង្កើនការយកចិត្តទុកដាក់លើការផ្សារភ្ជាប់វិធានការគោលនយោបាយ ទៅនឹងលទ្ធផលជាក់ស្តែង។

### ៤.២. ផែនការសកម្មភាព

**វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង** ដាក់ចេញនូវផែនការសកម្មភាព សម្រាប់អនុវត្តចាប់ផ្តើមពីត្រីមាសទី៤ នៃឆ្នាំ ២០២១ រហូតដល់ឆ្នាំ ២០២៣ និងមានកំណត់ច្បាស់លាស់អំពីការទទួលខុសត្រូវរបស់ ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ ដែលទទួលបន្ទុកលើការអនុវត្តនូវវិធានការគោលនយោបាយនីមួយៗ *(ដូចមានក្នុងឧបសម្ព័ន្ធ)*។

## ៥. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

កម្មវត្ថុនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺដើម្បីជំរុញសកម្មភាពពិភាក្សាឆ្លុះរកបញ្ហាប្រឈម, ដោះស្រាយបញ្ហាប្រឈម, ដាក់ចេញវិធានការកែតម្រូវ, វាស់វែងពីការខិតខំប្រឹងប្រែង និងវាយតម្លៃប្រសិទ្ធភាពនៃយន្តការអនុវត្ត វិធានការគោលនយោបាយដែលបានដាក់ចេញ ដោយមានការកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indicators-KPIs) និង វិធានការគោល-នយោបាយដែលត្រូវអនុវត្តគន្លឹះៗ ភ្ជាប់ដោយស្ថាប័នទទួលខុសត្រូវនាំមុខ។

វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនេះ ត្រូវតាមដាន និងវាយតម្លៃការអនុវត្តដោយ **គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍** ដោយមាន **ក្រុមការងាររាជរដ្ឋាភិបាលនិងឯកជនដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុងនិងក្រោយវិបត្តិនៃជំងឺកូវីដ-១៩** និង**គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត** ជាសេនាធិការដែលត្រូវអនុវត្តវិធានការគោលនយោបាយ និងសកម្មភាពនីមួយៗព្រមទាំងរៀបចំរបាយការណ៍លទ្ធផលជូន **គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍** ប្រចាំត្រីមាស, ឆមាស និងប្រចាំឆ្នាំ។ យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះមានការចូលរួមពីក្រសួង-ស្ថាប័នសំខាន់ៗ ដែលមានតួនាទីដូចខាងក្រោម÷

**-គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍** មានតួនាទី÷ **ទី១)**-ទទួលបន្ទុកចូលរួមក្នុងការតាមដាន និងវាយតម្លៃការអនុវត្តវិធានការ ដែលបានកំណត់ក្នុងវិធានការគោលនយោបាយនេះ ព្រមទាំងរៀបចំ និងពិនិត្យសម្រេចលើផែនការអនុវត្តវិធានការគោលនយោបាយផ្សេងទៀតតាមតម្រូវការជាក់ស្តែង ដោយមានការសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និង **ទី២)**-សហការជាមួយគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្នុងការតាមដានសភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដើម្បីពិនិត្យឡើងវិញជាប្រចាំលើវិធានការគោលនយោបាយ។

-**ក្រសួង-ស្ថាប័នទទួលបន្ទុកលើការអនុវត្តវិធានការគោលនយោបាយ** មានតួនាទី÷ **ទី១)**-រៀបចំផែនការអនុវត្តវិធានការគោលនយោបាយនិងរាយការណ៍ជូន គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ជាប្រចាំអំពីវឌ្ឍនភាពនៃការងារអនុវត្តវិធានការគោលនយោបាយទាំងនោះ និងធ្វើការកែសម្រួល

ផែនការរបស់ខ្លួន តាមការណែនាំរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ និង **ទី២)**-រៀបចំផែនការយុទ្ធសាស្ត្រត្រឡប់ដើម្បីត្រៀមខ្លួនសម្រាប់ករណីមានការផ្ទុះ និងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាទ្រង់ទ្រាយធំនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**-អាជ្ញាធរមូលដ្ឋាន និងគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត** មានតួនាទី÷ **ទី១)**-វាយតម្លៃជាប្រចាំអំពីស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងការអនុវត្តវិធានការរដ្ឋបាល និងសុខាភិបាលរបស់អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍ នៅតាមមូលដ្ឋានរបស់ខ្លួន, **ទី២)**-រាយការណ៍លទ្ធផលនៃការវាយតម្លៃនេះជូនគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ជាប្រចាំ និង **ទី៣)**-រៀបចំផែនការយុទ្ធសាស្ត្រត្រឡប់ដើម្បីត្រៀមខ្លួនសម្រាប់ករណីមានការផ្ទុះ និងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាទ្រង់ទ្រាយធំនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ៦. សន្និដ្ឋាន

នៅក្នុងបរិការណ៍ដែលកម្ពុជាបាន និងកំពុងត្រៀមបើកដំណើរការឡើងវិញនូវសកម្មភាពសង្គម-សេដ្ឋកិច្ចក្នុងប្រទេសឱ្យឈានទៅរកប្រក្រតីភាពថ្មី នាពេលឆាប់ៗខាងមុខនេះ, ការរៀបចំ "**វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣**" គឺជាកិច្ចការដ៏ចាំបាច់ និងទាន់ពេល ដើម្បីចូលរួមចំណែកក្នុងការស្តារវិស័យទេសចរណ៍កម្ពុជាក្នុងដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ ព្រមទាំងជាមូលដ្ឋានសម្រាប់ការត្រៀមបើកទទួលទេសចរណ៍អន្តរជាតិ នៅតាមតំបន់គោលដៅទេសចរណ៍សុវត្ថិភាពនាពេលខាងមុខ។

ភាពជោគជ័យនៃការអនុវត្តវិធានការគោលនយោបាយនេះ ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដោយឈរលើគោលការណ៍ភាពជាដៃគូ "**រដ្ឋ-ឯកជន-ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ-ដៃគូអភិវឌ្ឍ**" ដើម្បីជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ប្រកបដោយភាពជោគជ័យ និងសុវត្ថិភាព។ ជាមួយគ្នានេះ ភាពជោគជ័យនៃការអនុវត្តវិធានការគោលនយោបាយនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះក្នុងការបោះជំហានឆ្ពោះទៅរកការធានាបាននូវការស្តារឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យសង្គម-សេដ្ឋកិច្ចកម្ពុជាតាមគន្លងថ្មីនៃការអភិវឌ្ឍ៕

## ឧបសម្ព័ន្ធ. ផែនការសកម្មភាពនៃវិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង

| វិធានការគោលនយោបាយ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ស្ថាប័នទទួលបន្ទុក |
|---|---|---|---|---|
| **១. ការលើកកម្ពស់ទំនុកចិត្ត និងភាពជឿជាក់របស់ភ្ញៀវទេសចរផ្ទៃក្នុង** | | | | |
| **វិធានការទី១** | ──── | ──── | ───→ | -គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-រដ្ឋបាលថ្នាក់មូលដ្ឋាន<br>*(ដោយមានការគាំទ្រពីគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩)* |
| **វិធានការទី២** | ───→ | | | |
| **វិធានការទី៣** | ──── | ──── | ───→ | -ក្រសួងទេសចរណ៍<br>-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងធម្មការ និងសាសនា<br>-ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| **វិធានការទី៤** | | ──── | ───→ | -ក្រសួងទេសចរណ៍ |
| **វិធានការទី៥** | ──── | ──── | ───→ | -គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-រដ្ឋបាលថ្នាក់មូលដ្ឋាន |
| **វិធានការទី៦** | ───→ | | | -ក្រសួងសុខាភិបាល<br>-ក្រសួងទេសចរណ៍<br>-វិស័យឯកជន |
| **២. ការជំរុញដំណើរការឡើងវិញរបស់អាជីវកម្ម-ប្រតិបត្តិករទេសចរណ៍តាមគន្លងប្រក្រតីភាពថ្មី** | | | | |
| **វិធានការទី៧** | ──── | ──── | ───→ | -ក្រសួងសុខាភិបាល<br>-ក្រសួងទេសចរណ៍<br>-វិស័យឯកជន<br>-រដ្ឋបាលរាជធានី-ខេត្ត |
| **វិធានការទី៨** | ───→ | | | -ក្រសួងទេសចរណ៍<br>-ក្រសួងសុខាភិបាល<br>-ក្រសួងពាណិជ្ជកម្ម<br>-រដ្ឋបាលរាជធានី-ខេត្ត<br>-វិស័យឯកជន |
| **វិធានការទី៩** | ──── | ──── | ───→ | -អគ្គនាយកដ្ឋានពន្ធដារ<br>-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | |
|---|---|---|
| | | -ធនាគារសហគ្រាសធុនតូច និង មធ្យម កម្ពុជា |
| **វិធានការទី១០** | → | -ក្រសួងទេសចរណ៍<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ |
| **វិធានការទី១១** | → | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| **វិធានការទី១២** | → | -ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>-សហភាពសហព័ន្ធយុវជនកម្ពុជា<br>-មជ្ឈមណ្ឌលកម្ពុជា ៤.០<br>-វិស័យឯកជន |
| **៣. ការបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវទេសចរផ្ទៃក្នុង** | | |
| **វិធានការទី១៣** | → | -ក្រសួងទេសចរណ៍<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-វិស័យឯកជន |
| **វិធានការទី១៤** | → | -ក្រសួងទេសចរណ៍<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-វិស័យឯកជន |
| **វិធានការទី១៥** | → | -ក្រសួងទេសចរណ៍<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងមុខងារសាធារណៈ<br>-សហភាពសហព័ន្ធយុវជនកម្ពុជា<br>-វិស័យឯកជន |
| **វិធានការទី១៦** | → | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងមហាផ្ទៃ<br>-អគ្គស្នងការដ្ឋាននគរបាលជាតិ<br>-វិស័យឯកជន |
| **វិធានការទី១៧** | → | -ក្រសួងទេសចរណ៍<br>-ក្រសួងសាធារណការ និងដឹកជញ្ជូន |

| | | |
|---|---|---|
| | | -រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល<br>-រដ្ឋបាលរាជធានី-ខេត្ត<br>-ក្រុមហ៊ុនព្រលានយន្តហោះ (SCA)<br>-វិស័យឯកជន |
| **វិធានការទី១៨** | | -ក្រសួងទេសចរណ៍<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត |
| **វិធានការទី១៩** | | -ក្រសួងទេសចរណ៍<br>-គ្រឹះស្ថានអង្គរ |
| **៤. ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍បម្រើឱ្យចលនាទេសចរណ៍ផ្ទៃក្នុង** | | |
| **វិធានការទី២០** | | -ក្រសួងទេសចរណ៍<br>-ក្រសួងបរិស្ថាន<br>-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-វិស័យឯកជន |
| **វិធានការទី២១** | | |
| **វិធានការទី២២** | | |
| **វិធានការទី២៣** | | |
| **វិធានការទី២៤** | | |
| **វិធានការទី២៥** | | -ក្រសួងសាធារណការ និងដឹកជញ្ជូន<br>-ក្រសួងអភិវឌ្ឍន៍ជនបទ<br>-វិស័យឯកជន |
| **វិធានការទី២៦** | | -ក្រសួងទេសចរណ៍<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-វិស័យឯកជន |
| **វិធានការទី២៧** | | -ក្រសួង- ស្ថាប័នពាក់ព័ន្ធ<br>-វិស័យឯកជន |
| **វិធានការទី២៨** | | -ក្រសួងទេសចរណ៍<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-វិស័យឯកជន |
| **វិធានការទី២៩** | | -ក្រសួងមហាផ្ទៃ<br>-ក្រសួងទេសចរណ៍<br>-ក្រសួងបរិស្ថាន<br>-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |

| | | |
|---|---|---|
| | | -ក្រសួងធម្មការ និងសាសនា<br>-ក្រសួង- ស្ថាប័នពាក់ព័ន្ធ<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-រដ្ឋបាលរាជធានី-ខេត្ត<br>-វិស័យឯកជន |
| **៥. ការផ្សព្វផ្សាយ និងបញ្ច្រាបការយល់ដឹងជាសាធារណៈ** | | |
| **វិធានការទី៣០** | → | -ក្រសួងទេសចរណ៍<br>-ក្រសួងព័ត៌មាន<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត |
| **វិធានការទី៣១** | → | -ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា |
| **វិធានការទី៣២** | → | -ក្រសួងទេសចរណ៍<br>-គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-សហភាពសហព័ន្ធយុវជនកម្ពុជា<br>-រដ្ឋបាលរាជធានី-ខេត្ត |
| **វិធានការទី៣៣** | → | -គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានី-ខេត្ត<br>-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| **វិធានការទី៣៤** | → | -ក្រសួងទេសចរណ៍ |
| **វិធានការទី៣៥** | → | -ក្រសួងទេសចរណ៍<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងព័ត៌មាន |

# សេចក្តីថ្លែងអំណរគុណ

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និង **ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍** ចំពោះការណែនាំដល់ក្រុមការងាររៀបចំវិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣ ប្រកបដោយជោគជ័យ។

សូមគោរពជូនពរ ឯកឧត្តម សូមទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ។

## ក្រុមការងាររៀបចំវិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣

| | | |
|---|---|---|
| ១- | ឯកឧត្តម ណេប សាមុត | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាប្រធានលេខាធិការដ្ឋាននៃក្រុមការងារដើម្បីជំរុញ និងលើកស្ទួយវិស័យទេសចរណ៍ក្នុងដំណាក់កាលវិបត្តិ និងក្រោយវិបត្តិកូវីដ-១៩ |
| ២- | ឯកឧត្តម អាំង សុវណ្ណរ័ត្ន | អគ្គលេខាធិការរង គ.ជ.វ.ទ. និងជាអគ្គនាយករងអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ |
| ៣- | ឯកឧត្តម ជួន ជ័យសត្យា | អគ្គលេខាធិការរង គ.ជ.វ.ទ. និងជាប្រធាននាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ |
| ៤- | លោក សេង វិរៈយុទ្ធ | សមាជិកនៃលេខាធិការដ្ឋាននៃក្រុមការងាររាជរដ្ឋាភិបាល និងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ |
| ៥- | លោកស្រី ហេង ស្រស់ | អនុប្រធាននាយកដ្ឋានទីភ្នាក់ងារដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍ |
| ៦- | លោកស្រី មូល លីតា | អនុប្រធាននាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ |
| ៧- | កញ្ញា ចាន់ ថុនបញ្ញា | នាយការិយាល័យនៃនាយកដ្ឋានវាយតម្លៃក្រុងស្អាត |
| ៨- | លោក នៅ បញ្ញា | មន្ត្រីជំនួយការអគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |
| ៩- | កញ្ញា ហុង និមល | មន្ត្រីជំនួយការអគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |
| ១០- | លោក ទូច ផាន់ណា | មន្ត្រីជំនួយការអគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |

## ក្រុមការងារពិគ្រោះយោបល់

| | | |
|---|---|---|
| ១- | ឯកឧត្តម ផាន់ ផល្លា | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ២- | ឯកឧត្តម ហួត ពុំ | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៣- | ឯកឧត្តម ឈាង វណ្ណារិទ្ធ | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៤- | ឯកឧត្តម ទិត ចន្ថា | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ |
| ៥- | ឯកឧត្តម ជា ប៊ូរ៉ា | រដ្ឋលេខាធិការក្រសួងទេសចរណ៍ |
| ៦- | ឯកឧត្តម ជា កុសល | អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យក្រសួងទេសចរណ៍ |
| ៧- | ឯកឧត្តម ឆាយ យុនឡុង | ទីប្រឹក្សាក្រសួង និងជាអគ្គនាយករងគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |
| ៨- | ឯកឧត្តម គឹម សេរីរដ្ឋ | អគ្គលេខាធិការរង គ.ជ.វ.ទ. និងជាប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ |

# រៀបចំដោយ

ក្រុមការងាររាជរដ្ឋាភិបាលនិងឯកជន ដើម្បីស្តារ
និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា
ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩

MINISTRY OF TOURISM

MINISTRY OF ECONOMY AND FINANCE

# សូមថ្លែងអំណរគុណ

គណៈកម្មការអប់រំ យុវជន កីឡា
ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍